# ទស្សនទាន
# ព្រឹត្តិការណ៍តាំងពិព័រការងារ និងការសិក្សា

**កាលបរិច្ឆេទ** ៖ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៦ ចាប់ពីម៉ោង ៨.០០ ព្រឹក ដល់ម៉ោង ១២.០០ នាទី ថ្ងៃត្រង់
**ទីតាំង** ៖ សាខាសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាប
**អ្នកចូលរួម** ៖ ៦៤០នាក់

## សេចក្តីផ្តើម

កម្មវិធីគ្រប់គ្រងក្តីប្រាថ្នា បានបង្កើតឡើងក្នុងឆ្នាំ២០១២ ដោយបានអនុវត្តនៅក្នុងវិទ្យាល័យ ក្រឡាញ់ ហើយកម្មវិធីបានពង្រីកវិទ្យាល័យគោលដៅរបស់ខ្លួនទៅកាន់វិទ្យាល័យ សែនសុខ និងវិទ្យាល័យ វ៉ារិន ក្នុងឆ្នាំសិក្សា២០១៩ - ២០២០។ ក្នុងឆ្នាំសិក្សាថ្មី ២០២៣-២០២៤ ផេពភី បានពង្រីកតំបន់គោលដៅទៅស្រុកចំនួន៥ ថែមទៀតគឺ៖ ស្រុកពួក ស្រុកអង្គរជុំ ក្រុងរុនតាឯកតេជោសែន ស្រុកជីក្រែង និងស្រុកបន្ទាយស្រី និងមានវិទ្យាល័យដៃគូសរុបចំនួន ១២ ក្នុងខេត្តសៀមរាប ដោយមានគោលបំណង "**ដើម្បីពង្រីកឱកាសអប់រំសម្រាប់សិស្សបញ្ចប់ការសិក្សាក្នុងកម្មវិធី "គ្រប់គ្រងក្តីប្រាថ្នា" ដោយបង្កើតឱ្យមានវប្បធម៌ជំរុញលើកទឹកចិត្ត ឱ្យពួកគេបន្តការសិក្សាថ្នាក់ឧត្តមសិក្សា ឬសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលសមស្របនឹងចំណង់ចំណូលចិត្តរបស់ពួកគេ**"។ នៅក្នុងឆ្នាំសិក្សាចាស់កន្លងទៅ កម្មវិធីបានបញ្ចប់វគ្គសិក្សាដោយជោគជ័យដោយទទួលបានលទ្ធផល និងការគាំទ្រយ៉ាងកក់ក្តៅពីសំណាក់គណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងអាណាព្យាបាល ដើម្បីគាំទ្រសិស្សានុសិស្សក្នុងវិទ្យាល័យ។ ផេពភី និងគណៈគ្រប់គ្រងសាលា គ្រោងនឹងរៀបចំ នឹងដឹកនាំសិស្សានុសិស្សថ្នាក់ទី១២ ចូលរួមព្រឹត្តិការណ៍តាំងពិព័រការងារ និងការសិក្សា នៅក្នុងខេត្តសៀមរាប ចំនួន ១លើក មកពីវិទ្យាល័យចំនួន ៧ រួមមានវិទ្យាល័យក្រឡាញ់ វិទ្យាល័យសែនសុខ វិទ្យាល័យរើល វិទ្យាល័យវ៉ារិន វិទ្យាល័យស្ពានត្នោត វិទ្យាល័យ ហ៊ុន សែន ពង្រលើ និងវិទ្យាល័យ ហ៊ុន សែន ព្រះធាតុ។ ព្រឹត្តិការណ៍នេះ មានការអញ្ជើញចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាល សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សាកលវិទ្យាល័យ វិទ្យាស្ថាន ក្រុមហ៊ុន និងសណ្ឋាគារក្នុងខេត្តសៀមរាបជាង ៣០ស្ថាប័ន ដោយមានការដាក់តាំងបង្ហាញពីអង្គភាពនីមួយៗដើម្បីឱ្យសិស្ស អាចសាកសួរព័ត៌មានផ្សេងៗទាក់ទងនឹងការងារ ការសិក្សាក្នុងស្រុក និងឱកាសអាហារូបករណ៍ ជាដើម។

## គោលបំណង

សិស្សានុសិស្សទទួលបានឱកាសឈ្វេងយល់ និងរៀនសូត្រតាមរយៈជួបដោយផ្ទាល់ជាមួយបណ្តាអង្គការ ក្រុមហ៊ុន ធនាគារ វិទ្យាស្ថាន សាកលវិទ្យាល័យ ហើយសិស្សានុសិស្សអាចសាកសួរព័ត៌មានផ្សេងៗទាក់ទងនឹងការងារ ការសិក្សា និងឱកាសអាហារូបករណ៍ ជាដើម។

## ការត្រៀមលក្ខណៈសម្រាប់ការចូលរួម

- សម្រាប់ លោកគ្រូអ្នកគ្រូ និងបុគ្គលិកអង្គការផេពភី អាចប្រើប្រាស់សម្លៀកបំពាក់សមរម្យ។
- សម្រាប់សិស្សានុសិស្សតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានសិស្ស និងស្បែកជើងសមរម្យ។

**សមាសភាពអ្នកចូលរួម** (សរុបចំនួន ៦៤០នាក់)

១. ប្រធាន ឬតំណាងការិយាល័យអប់រំ យុវជន និងកីឡា ខេត្តសៀមរាប ចំនួន ១នាក់
២. នាយកនាយិកា វិទ្យាល័យចំនួន ៧នាក់
៣. លោកគ្រូអ្នកគ្រូ វិទ្យាល័យចំនួន ២០នាក់ (អាស្រ័យលើការរៀបចំរបស់សាលា)
៤. លោកគ្រូអ្នកគ្រូបង្គោលក្នុងកម្មវិធីគ្រប់គ្រងក្ដីប្រាថ្នា ចំនួន ១៨នាក់
៥. បុគ្គលិកអង្គការផេពកី និងបុគ្គលិកស្ម័គ្រចិត្តចំនួន ១០នាក់
៦. សិស្សានុសិស្សចំនួន ៤២៤នាក់
៧. សិស្សនិស្សិតចំនួន ១៦០នាក់

**របៀបវារៈ**

| ម៉ោង | ខ្លឹមសារ សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៦.០០-៨.០០ ព្រឹក | ការអញ្ជើញដល់របស់គណៈអធិបតី ភ្ញៀវកិត្តិយស និងក្រុមហ៊ុន | ក្រុមសិស្សស្ម័គ្រចិត្ត |
| ៨.០០-៨.១០ ព្រឹក | ប្រកាសហេតុ ប្រកាសគណៈអធិបតី គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងគោរពវិញ្ញាណខ័ន្ធវីរៈកងទ័ព | ពិធីករ និងពិធីការនី |
| ៨.១០-៨.២០ ព្រឹក | ការសម្ដែង របាំជូនពរ | ក្រុមសិស្សស្ម័គ្រចិត្ត |
| ៨.២០-៨.៣០ ព្រឹក | របាយការណ៍សង្ខេប | នាយកគ្រប់គ្រង<br>អង្គការ លើកកម្ពស់យុវជន |
| ៨.៣០-៨.៤០ ព្រឹក | មតិចំណាប់អារម្មណ៍ | លោកនាយកសាខា សាកលវិទ្យាល័យ<br>បៀលប្រាយ ខេត្តសៀមរាប |
| ៨.៤០-៨.៥០ ព្រឹក | សុន្ទរកថាស្វាគមន៍ និងប្រកាសបើកកម្មវិធី | លោកប្រធានមន្ទីរ<br>អប់រំ យុវជន និងកីឡា ខេត្តសៀមរាប |
| ៨.៥០-៩.១០ ព្រឹក | ការប្រគល់លិខិតថ្លៃអំណរគុណជូនដល់ស្ថាប័ន និងថតរូបអនុស្សាវរីយ៍ | គណៈអធិបតី ភ្ញៀវកិត្តិយស |
| ៩.១០-១១.០០ ព្រឹក | ការទស្សនាតាមស្តង់ពិព័រនីមួយៗ បទបង្ហាញតម្រង់ទិសរបស់វាគ្មិន | គណៈអធិបតី ភ្ញៀវកិត្តិយស និងសិស្សានុសិស្ស |
| ១១.០០-១១.៤០ ថ្ងៃត្រង់ | ឆ្លុះបញ្ចាំងអំពីលទ្ធផលបន្ទាប់ពីការទស្សនាតាមស្ថាប័ននានារបស់សិស្សានុសិស្ស (សំណួរចម្លើយ) | អ្នកសម្របសម្រួលកម្មវិធី |
| ១១.៤០-១២.០០ ថ្ងៃត្រង់ | បូកសរុប និងប្រកាសបិទកម្មវិធី | អ្នកសម្របសម្រួលកម្មវិធី |

*ចំណាំ៖ ក្រុមការងាររបស់អង្គការលើកកម្ពស់យុវជន សូមរក្សាសិទ្ធិកែប្រែ ប្រសិនបើមានភាពចាំបាច់។*